# ការសំភាសន៍របស់អ៊ុំស្រី យិន រន

**ក៖ អ្នកសម្ភាស ៖ លន់ មុណារក់** **ខ៖ អ្នកដែលត្រូវគេសម្ភាស៖ យិន រន**

## ពត៍មានសង្ខេបរបស់អ៊ុំស្រី យិន រន

ក៖ អ៊ុំស្រី៖ យិន រន: មានទីលំនៅបច្ចុប្បន្ននៅប្រទេសកម្ពុជា នៅខេត្តបាត់ដំបង ភូមិអូរដំបង ឃុំអូរដំបងពីរ ស្រុកសង្កែ ខេត្តបាត់ដំបង។ ហើយនៅក្នុងគ្រុមគ្រួសាររបស់អ៊ុំស្រី អ៊ុំស្រីមានបងប្អូន ពីរនាក់ ហើយអ៊ុំស្រីជាកូនពៅ។ ហើយឆ្នាំនេះអ៊ុំមានអាយុ ៥៧, ហើយអ៊ុំជាស្ត្រីក្រមុំចាស់រស់នៅជាមួយនឹងបងប្អូន។

ក៖ ជាដំបូងខ្ញុំសូមជំរាបសួរអ៊ុំ។

ខ៖ ចាស! អាយុវែង។

ក៖ ចាស! ខ្ញុំមកពីខាងសាលាសាកលវិទ្យាល័យមួយនៅសហរដ្ឋអាមេរិច គេបានអញ្ជើញខ្ញុំមកថ្ងៃនេះដើម្បីធ្វើការសម្ភាសប្រជាជនខ្មែរហើយនឹងអ៊ុំស្រីថ្ងៃផ្ទាល់។ ខ្ញុំចង់សួរអ៊ុំខ្លះពីជីវៈប្រវត្តិហើយនឹងជីវភាពរបស់អ៊ុំកាលពីសម័យនឹងតើអ៊ុំបានឆ្លងកាត់នូវការលំបាកអ្វីខ្លះ ហើយតាំងពីតូចរហូតមកដល់ធំប៉ុននេះតើអ៊ុំបានឆ្លងកាត់នូវការលំបាកអ្វីខ្លះ។?

ខ៖ ចាស!

ក៖ ចាស! អញ្ចឹងតើខ្ញុំសូមធ្វើការសម្ភាសហើយសួរអ៊ុំខ្លះពីខ្សែជីវិតរបស់អ៊ុំនៅពេលនឹងតើបានដែលឬទេអ៊ុំ?

ខ៖ ចាសបាន។

ក៖ ចាសអញ្ចឹងអរគុណច្រើនអ៊ុំ។ អញ្ចឹងខ្ញុំអ្នកសម្ភាសអ៊ុំនីថ្ងៃនេះខ្ញុំមានឈ្មោះលន់ មុណាក់។ ហើយថ្ងៃនេះជាថ្ងៃអទី ២៩ ខែ ០៥ ឆ្នាំ ២០២០។

ខ៖ ចាស!

ក៖ អញ្ចឹងតើអ៊ុំស្រីមានឈ្មោះអ្វីដែល?

ខ៖ ខ្ញុំឈ្មោះ យិន រន។

ក៖ យិន...?

ខ៖ យិន រិន។

ក៖ យិន រ៉ែន?

ខ៖ យិន រន, រ ហើយ នឹង ន។

ក៖ ចាសអ៊ុំ! អញ្ចឹងតើអ៊ុំឈ្មោះគេហៅក្រៅអ្វីផ្សេងពីនឹងទៀតដែឡឬអត់?

ខ៖ អត់! អត់មានផង។ មានឈ្មោះតែមួយនឹងគត់។

ក៖ អញ្ចឹងមានឈ្មោះតែមួយនឹងទេន៍អ៊ុំ?

ខ៖ ចាសនឹងហើយ!

ក៖ ចាស! អញ្ចឹងតើអ៊ុំ ឆ្នាំនេះអ៊ុំមានអាយុប៉ុន្មានដែលហើយ?

ខ៖ ឆ្នាំនេះ អាយុ ៥៧។

ក៖ ៥៧ ហើយន៍អ៊ុំ?

ខ៖ ចាស!

ក៖ អ៊ុំមើលទៅនៅក្មេងខ្ញុំស្មានតែអ៊ុំអាយុ ៤០ ចាងតើ។

ខ៖ ហាហា...! (មិត្តភ័ក្កគាត់ោសួរ)....។

ក៖ ចាស! អញ្ចឹងក្រៅពីភាសាខ្មែរតើអ៊ុំមានចេះភាសាអ្វីផ្សេងពីភាសាខ្មែរទៀតដែលឬអត់?

ខ៖ អត់អត់ចេះសោះម៉ង, ភាសាខ្មែរអក្សរមិនតង់ចេះផង។ ចេះតែនិយាយនឹង។

កៈ ចេះតែនិយាយទេន៏អ៊ុំ?

ខៈ ចាស!

កៈ ចាស!។

ខៈ ប៉ុន្តែបានមើលឈ្មោះខ្លួនឯងដាច់។

កៈ ចាសចាស!

ខៈ គ្រាន់តែដឹងអញ្ចឹងហាស់?

កៈ ចាសអ៊ុំ!

ខៈ ដឹង, ដឹងឈ្មោះខ្លួនឯង។

កៈ ចាសអ៊ុំ! អញ្ចឹងតើអ៊ុំមានចាំថ្ងៃខែឆ្នាំដែលអ៊ុំបានរៀបការទេ?

ខៈ អ៊ុំអត់មានផង! អ៊ុំរស់នៅតែឯងរហូត។

កៈ អូ!! អ៊ុំអត់មានគ្រុមគ្រួសារទេ? នៅម្នាក់ឯង។

ខៈ ចាស! នៅម្នាក់ឯងរហូត។ នៅជាមួយពុកម៉ែដល់ពេលពុកម៉ែពួកគាត់ខូចអស់ទៅនៅតែម្នាក់ឯង។

កៈ ចាសអ៊ុំ! តើអ៊ុំអត់ចង់យកគ្រួសារឬក៏យ៉ាងម៉េច?

ខៈ អ៊ុំមិនថាអត់ចង់ទេ! ប៉ុន្តែដល់ពេលកេមកវាអត់ល្អ! ចឹងទៅអត់យក។ វាអញ្ចឹងហាស់តាំងពីក្មេងមក។

កៈ ចាសអ៊ុំ!

ខៈ ដល់ពេលអញ្ចឹងទៅអ៊ុំខ្ជិលហើយក៏នៅតែម្នាក់ឯងប៉ុនដោយទៅ។

កៈ ចាសហ៊ឹម...! តើស្រួយដែលទេអ៊ុំ?តើអ៊ុំស្រឡាញ់ជីវិតបែបនេះទេ?

ខៈ ចង់និយាយថាស្រួយក៏បានដែលក្មួយ, ចង់និយាយថាពេលដែលយើងឈឺហាស់?

ក៖ ចាសអ៊ុំ!

ខ៖ អ៊ុំធ្លាប់ឆ្លងកាត់, នេះនេះធ្លាប់មកគេងនៅនេះ បងសេងគាត់ដាំទឹក ដាំបបរអោយហូប ហើយក្មួយមួយទៀតបោកខោអាវអោយ។

ក៖ ចាសចាសអ៊ុំ!

ខ៖ ហើយខ្ញុំផ្ទះនៅនោះទេ។

ក៖ ចាសអ៊ុំ!

ខ៖ ប៉ុន្តែខ្ញុំមកអញ្ចឹង, ខ្ញុំឆ្លងកាត់នៅពេលដែលខ្ញុំឈឺហាស់?

ក៖ ចាស!

ខ៖ ចាស វាពិបាក។

ក៖ ចាសអ៊ុំ!

ខ៖ (គាត់កំពុងនិយាយជាមួយនឹងមិត្តភ័ក្តរបស់គាត់)....!៕

ក៖ ចាស! អញ្ចឹងមីង, អញ្ចឹងមិនមែនមីងមិនចង់បាននោះតេ គ្រាន់តែអ្នកដែលចូលមកដណ្តឹងមីងនឹងពួកគេជាមនុស្សមិនល្អ?

ខ៖ ចាស ចាស! អញ្ចឹងយើងមើលទៅ យើងដឹង មិនអាចយកបានអញ្ចឹងយើងក៏អត់យកទៅ៕

ក៖ ចាស! សុខចិត្តនៅម្នាក់ឯង។?

ខ៖ ចាសសុខចិត្តរស់នៅម្នាក់ឯង។

ក៖ ចាស! អញ្ចឹងមីងមានអារម្មណ៍ថាស្តាយក្រោដែលឬទេការសម្រេចត្តរបស់មីងនីពេលនឹង?

ខ៖ ចង់និយាយថាវាស្តាយក្រោយស្តាយដែល។ ប៉ុន្តែមិនដឹងថាធ្វើយ៉ាងម៉េចបើវាហួសហើយណាស់។

ក៖ ចាសមីង!

ខ៖ ចង់និយាយថាយើងវាចាស់ហើយ! វាហួសហើយណាស់។

ក៖ ទៅក្រោយលែងរួចហើយ។

ខ៖ ចាសនឹងហើយ! វាមិនអាចទៅបាន។

ក៖ ចាសមីង!

ខ៖ ដល់ពេលអញ្ចឹងទៅតាមដំណើរទៅ។

ក៖ ចាស! តែបើអាចមីងជ្រើសរើសយកគ្រុមគ្រួសារវិញន៍មីង?

ខ៖ ចាស! អាចដែលនឹងឯង។ តែយើងវាមិនអាចដោយសារតែយើងចាសដែលហើយ។

ក៖ ចាសចាសមីង!

ខ៖ ដល់ពេលអញ្ចឹងទៅខ្ចិល។ តាមដំណើរទៅ តាមមក្មរបស់យើងទៅ ផ្សងសំណាង។

ក៖ ចាសមីង! អញ្ចឹងតើនៅក្នុងសមាជិកគ្រុមគ្រួសាររបស់អ្នកមីងតើអ្នកមីងមានបងប្អូនប៉ុន្មានអ្នកដែល?

ខ៖ បងប្អូនគេបែកអស់ហើយ! នៅតែមីងម្នាក់ឯង។

ក៖ ចាស! អញ្ចឹងមានពីរនាក់?

ខ៖ ចាស!

ក៖ ពីរនាកើបងប្អូន?

ខ៖ ចាសចាស!

ក៖ អញ្ចឹងមីងជាកូនពៅហើយចឹង?

ខ៖ ចាស!មីងកូនពៅ។

ក៖ ចាស! អញ្ចឹងបងរបស់មីងតើគាត់មានអាយុប៉ុន្មានហើយ?

ខ៖ បងខ្ញុំគាត់៦០។

ក៖ ៦០ គត់, ហើយមីង ៥៧?

ខ៖ ចាស!

ក៖ ចាស! អញ្ចឹងបងបីឆ្នាំ?

ខ៖ ចាស! បងបីឆ្នាំ។

ក៖ ចាសបងបីឆ្នាំ!

ខ៖ បងខ្ញុំប្ដីពេទ្យលី។

ក៖ អូរ!!!

ខ៖ ចាស! នឹងហើយបងរបស់ខ្ញុំហ្វ!!

ក៖ ចាស!!! ខ្ញុំអត់ដឹងទេបើមីងអត់ប្រាប់ខ្ញុំ។

ខ៖ ចាសនឹងហើយ! បងខ្ញុំបង្កើតនឹងហាស់?

ក៖ ចាស!

ខ៖ ប្ដីពេទ្យលីនឹងឯង។ ហើយពេទ្យលីគាត់ជាបងថ្លៃរបស់ខ្ញុំ។

ក៖ ចាស! ហ៊ឹម..! ចាសអញ្ចឹងនៅជុំគ្នាទាំងអស់?

ខ៖ ចាស! នេះខ្ញុំមកលេងទេ។ ខ្ញុំមកជួយគាត់នេះ, ខ្ញុំមកជួយចិត្តស្វាយចិតអីអោយគាត់ហើយខ្ញុំទៅវិញហាស់៕ ដល់ពេលល្ងាចឡើងខ្ញុំទៅវិញហើយ។

ក៖ ចាសចាសមីង!។

ខ៖ ចេញទៅវិញ។

ក៖ ចាសចាស! អូនេះមីងមកលេង។

ខ៖ ចាស! ខ្ញុំនៅដីគែនឹង។

ក៖ ចាស!

ខ៖ ផ្ទះរបស់ខ្ញុំដែលខ្ញុំនៅសព្វថ្ងៃនឹងក៏ជាដីរបស់គែដែល។

ក៖ ចាសមីង!

ខ៖ ប៉ុន្តែភូមិអោយខ្ញុំវាស់ដែលតើ តែខ្ញុំនឹកឃើញថាខ្ញិល, ខ្ញុំមកមិនអាចយករបស់កេបានចឹង ហាស់ទៅខ្ញុំខ្ញិល។

ក៖ ចាសមីង!

ខ៖ ខ្ញុំសុខចិត្តសុំគេស្នើសុំឪពុកគែនឹងហាស់?

ក៖ ចាសមីង!

ខ៖ ឪពូកគាត់នឹងហាស់។ ឪពុកប្ញ៉ាន។

ក៖ ចាស!

ខ៖ អញ្ចឹងនឹកឃើញថាខ្ញិលហាស់ យើងសូមគាត់ម៉ានៅ, ដល់ពេលភូមិឃុំគេមកអោយវាស់។ អោយវាស់ទៅចង់ធ្វើប៉ុនណាអីប៉ុនណាចឹងហាស់។ តាំងតែពីឆ្នាំ ៧៩ម្លេះ

ក៖ ចាស!

ខ៖ តែខ្ញុំខ្ញិល! ខ្ញុំអត់ត្រូវការ ខ្ញុំអត់ចង់បានរបស់គេចឹងហាស់។

ក៖ ចាសមីង!

ខ៖ ខ្ញមចង់និយាយថា សុំគេនៅរហូតដល់ងាប់ប៉ុនដោយហាស់?

ក៖ ចាសមីង!

ខ៖ ដល់ពេលងាប់ទៅ អោយគេទៅ។

ក៖ ចាសមីង!

ខ៖ ចាសអញ្ចឹងឯងបាន! ម្នាក់នឹងថាហ៊ឹម..វាគ្មានហាស់៕

ក៖ ចាសមីង!

ខ៖ ម៉ាប្រវត្តិសាស្រ្តហើយមិនដែលមានទេមានតែខ្ញុំមួយ។ ខ្ញុំថាខ្ញុំមិនអាចទេដោយសារតែឪពុកម៉ែខ្ញុំសូមគេនៅ។

ក៖ ចាសមីង!

ខ៖ ហើយដល់ពេលអោយវាស់អញ្ចឹងយកអញ្ចឹងខ្ញុំមិនអាចធ្វើបានទេ។ ខ្វិល..

ក៖ ចាសមីង! ក៏អត់ទៅន៏មីង?

ខ៖ ចាស! អត់សព្វថ្ងៃនេះមកតែនេះឯង។ដើរលែង។

ក៖ ចាស!

ខ៖ ម៉េចម៉ា...! មិនដឹងថាម៉េចទេ តែតាមដំណើរចុះ។

ក៖ ចាសមីង! អញ្ចឹងពេលដែលមីងកើតខ្ញុំងត់បានសួរមីង។ អញ្ចឹងមីងកើតនៅភូមិអូរដំបងនេះដែលមែណាទេមីង?

ខ៖ កំណើតហី?

ក៖ ចាសមីង!

ខ៖ កំណើតនៅអូរសោឡៀទេ។

ក៖ អូ!!!

ខ៖ តែដល់ពេលមកអូរដំបងនេះ, មាខ្ញុំនឹងហាស់?

ក៖ ចាសមីង!

ខ៖ គាត់ថាខ្វិលរញ៉េរញ៉ៃទៅ ក៏ដាក់អូរដំបងប៉ុនដោយទៅ។

ក៖ អូ!!

ខ៖ អញ្ចឹងហាស់?

ក៖ ចាសមីង!

ខ៖ គាត់ស្រឡាញ់ខ្ញុំហាស់?

ក៖ ចាស!

ខ៖ គាត់ស្រឡាញ់ខ្ញុំហាស់។ គាត់ថាខ្ចិលកុំអោយរញ៉េរញ៉ៃដាក់ភូមិកំណើតនៅអីរដើបងប៉ុនដោយទៅ។

ក៖ ចាសនៅអូរដំបង។

ខ៖ ដាក់ផ្ទះដែលខ្ញុំនៅនឹងហើយដីនឹងប៉ុនដោយ។

ក៖ ចាសមីង!

ខ៖ ចុះបើគាត់ស្រឡាញ់យើងចឹងហាស់។

ក៖ ចាសមីង!

ខ៖ តាមពិតទៅភូមិកំណើតរបស់ខ្ញុំគឺនៅនឹងអូរសាឡៅទេ។

ក៖ ចាសមីង!

ខ៖ អញ្ចឹងបានជាខ្ញុំអត់អាចយកដីកូនចៅនឹងបានអញ្ចឹង, ដោយសារតែឪបុកនឹងគាត់ស្រឡាញ់ខ្ញុំណាស់ប៉ុនដោយហាស់?

ក៖ ចាសមីង!

ខ៖ អញ្ចឹងបានថាវាមិនអាចលេចរួចអញ្ចឹងហាស់។

ក៖ ចាសមីង!

ខ៖ អញ្ចឹងខ្ចិល។ តាមតំណើរទៅងាប់ថ្ងៃណាចោលថ្ងៃនឹងទៅ, ខ្ញុំខ្ចិល។

ក៖ ហ៊ឹម..ចាស! នឹងហើយមីង។

ខ៖ ចាស!

ក៖ និយាយទៅល្អដែលដែលមីងនៅអាចពឹងពាក់គេបានចឹងហាស់។

ខ៖ ចាស! អញ្ចឹងបានជាគេស្រឡាញ់អញចឹង, គេថាមិនដែលមានមនុស្សណាមកនៅហើយមិនយកហាស់?

ក៖ ចាសមីង!

ខ៖ គេសើសើរយើងត្រង់នឹង! ហើយខ្ញុំថាខ្ញុំអត់យកទេ។

ក៖ ចាសមីង!

ខ៖ ចាស!

ក៖ សុំតែមួយរស់ទេន៏មីង?

ខ៖ ចាសនឹងហើយសុំតែមួយរស់ទេ។ ពេលដែលងាប់យកតៅវិញទៅកូនចៅយកទៅវិញទៅ។

ក៖ ចាសមែននេងមីង! ព្រោះអីមីងតែឯងហ្ង.! អត់ត្រូវមានចែកទៅណាអីទៀតផង។

ខ៖ ចាស! អត់ទេ។ ហើយឪពុកគែនឹងក៏គេថាដែល៖ អាញ់សូមអោយវានៅ បើសិនជាវាមានគ្រួសារចង់នាំគ្រួសារមកនៅក៏អោយនៅទៅ, ហើយបើសិនជាវាមិនយកទេក៏ហីទៅ។ ខ្ញុំអត់ដល់ឥឡូវ។

ក៖ ចាសមីង! នឹងហើយមីងអញ្ចឹងតើឪពូកម្ដាយរបស់មីងតើពួកគាត់មានឈ្មោះអ្វីដែលមីង?

ខ៖ ឪពុកឈ្មោះ៖ ពើងយិន ម្ដាយឈ្មោះ ៖ ខុយពណ៌។

ក៖ ចាសមីង!

ខ៖ ពណាក៏បាន ពណ័ក៏បាន។

ក៖ ចាសមីង!

ខ៖ ពណានិងពណ៌ដូចតែគ្នា។

ក៖ ចាស! អញ្ចឹងតើមីងមានចាំកន្លែងកំណើតរបស់ពួកគាត់ដែលឬទេ? កន្លែងកំណើតកើតរបស់គាត់ហាស់?

ខ៖ អូ!! កំណើតគាត់...! ពើងឃិននេះនៅនឹងអូរជំពងនេះឯង, ប៉ុន្តែ ខិយពណ៍នៅអូរសាទ្បៅ។

ក៖ ចាសនឹងម្ដាយរបស់មីង?

ខ៖ ចាស! តែឪពុកនៅអូរដំបងនេះឯង៕

ក៖ ចាស! អញ្ចឹងឥឡូវនេះតើពួកគាត់មានអាយុប៉ុន្មានអស់ហើយមីង?

ខ៖ ពួកគាត់ហ្ហ? មើលពួកគាត់ខូច..ឪពុករបស់ខ្ញុំខូចនៅអាយុ៨៨។

ក៖ ចាស!

ខ៖ ២០០៣ ឪពុកខូចហាស់។?

ក៖ ចាសមីង!

ខ៖ បើម៉ែគាត់ខូច ៨៧ គាត់អាយុ៦២។

ក៖ ចាសមីង!

ខ៖ ខ្មោចម៉ែរបស់ខ្ញុំហាស់?

ក៖ ចាសមីង!

ខ៖ ខ្មោចម៉ែរបស់ខ្ញុំគាត់ខូចនៅអាយុ ៦២។

ក៖ ចាសមីង!

ខ៖ ខ្មោចម៉ែរបស់ខ្ញុំហាស់! គាត់ខូចមុន។

ក៖ ចាសមីង! គាត់ខូចដោយសារតែជំងឺឬក៏ម៉េចដែលមីង?

ខ៖ ជំងឺ, ជំងឺ..!

ក៖ តើគាត់កើតអីដែល?

ខ៖ គាត់កើតរបែង, គាត់ក្អក។

ក៖ អូចាស!!

ខ៖ គាត់ក្អកគាត់របែង។

ក៖ ចាស!

ខ៖ ចាស! ហើយដល់ពេលឪពុករបស់ខ្ញុំវិញគាត់ចាស់ជរាប៉ុនដោយ។

ក៖ ចាសមីង!

ខ៖ ចាស! អាយុគាត់ខ្ទួច ៨៨។

ក៖ ចាសគាត់ខ្ទួចចាស់ដែលហើយន៏មីង?៕

ខ៖ ចាស! ចាស់ហើយ៨៨ឆ្នាំហើយ។

ក៖ ចាស! គាត់ចាស់ហើយ

ខ៖ ចាសគាត់ចាស់ហើយ!

ក៖ ចាស!

ខ៖ ចាស៕

ក៖ អញ្ចឹងមីងនៅទាន់គាត់ទាំងអស់ន៏មីង?

ខ៖ ចាស! ខ្ញុំតាន់គាត់ទាំងអស់នឹងឯង។

ក៖ ចាស!

ខ៖ ខ្ញុំនេះឯងជាអ្នកនៅគ្រប់...

ក៖ មើលថៃពួកគាត់?

ខ៖ ចាស! បើម៉ែថៃបានតិចទេ។

ក៖ ចាសមីង!

ខ៖ ចុះបើគាត់អាយុ៨៧អញ្ចឹងគាត់រហ័សខូចអញ្ចឹងហាស់៕

ក៖ ចាសមីង! គាត់រហ័សស្លាប់។

ខ៖ ចាស!ដល់ពេលឪពុករបស់ខ្ញុំវិញខ្ញុំនៅបំរើគាត់បានយូរ។ បំរើបានយូរ។

ក៖ ចាសមីង។

ខ៖ គាតៅ២០០៣បានគាត់ខូចហាស់?

ក៖ ចាសមីង!

ខ៖ ឆ្នាំរ៉ែក,

ក៖ ចាស!

ខ៖ ម៉ែរបស់ខ្ញុំខូចនៅឆ្នាំ ៨៧ ខូចនៅឆ្នាំឆ្លូវហី...? វាភ្លេចទៀតណាស់។

ក៖ ចាស!

ខ៖ បែបនៅឆ្នាំឆ្លូវ ៨៧ ដូចជាឆ្នាំឆ្លូវនោះ?

ក៖ ចាស! ប្រហែលនឹងឯង. ឆ្លូវចាស។

ខ៖ ចាស!ចាស ខ្ញុំជឿថាឆ្លូវហើយ ព្រោះអីវា៨៧ ហែងយកទៅគុណទៅ គុណទៅដឹងហើយ។ ឆ្នាំ៨៧ គាត់ខូច។

ក៖ ចាសមីង!

ខ៖ ប៉ុន្តែបើឪពុកខ្ញុំវិញខ្ញុំច្បាស់ប៉ុនដោយ ព្រោះអ្វីគាត់ស្លាប់នៅឆ្នាំ ២០០៣។

ក៖ ចាសមីង!

ខ៖ ម៉ែខ្ញុំក៏ទាន់ដែលចង់និយាយថា, ពេលដែលយួនចូលមកខ្ញុំបំរើគាត់បានតិចចឹងហាស់៕

ក៖ ចាសមីង!

ខ៖ ប៉ុន្តែបើឪពុកខ្ញុំបំរើគាត់បានយូរ។

ក៖ ចាសនឹងហើយមីង!

ខ៖ ចាស!

ក៖ នឹងហើយអ៊ុំ។

ខ៖ ចាស!

ក៖ អញ្ចឹងតើឪពុកម្តាយរបស់អ៊ុំ, បានប្រាប់អ៊ុំយ៉ាងម៉េចដែលពីប្រវត្តិសហ្ការរបស់ពួកគាត់ហាស់? តើពួកគាត់បាននិយាយប្រាប់អ៊ុំដែលឬទេ?

ខ៖ គាត់ស្រឡាញ់គ្នា! គាតស្រឡាញ់គ្នា។

ក៖ ចាស ហើយគាតោបានជួបគ្នាម៉េចដែល?

ខ៖ ចាសគាត់ថាគាត់ស្រឡាញ់ចឹង។

ក៖ អូចាស! ហាហា..ជួបទៅស្រឡាញ់ហើយយកការប៉ុនដោយ?

ខ៖ ចាស! ដូចថា..

ក៖ លឿងណាស់អ៊ុំនោះ?

ខ៖ ចាសនឹងហើយ! ចុះបើគាត់ថាអញ្ចឹងហូ?!

ក៖ ចាស!

ខ៖ អរ!!! គាត់ថាស្រឡាញ់គ្នាអញ្ចឹងទៅយកហើយ គាត់យកបានខ្ញុំពីរនឹងឯង។

ក៖ ចាស!

ខ៖ ពីរនឹង! ប្ដីពេទ្យលីនឹងឯង។ ហាហា...!

ក៖ ចាស! ហាហាហា..

ខ៖ ចាស

ក៖ ចាសឯត់មានច្រើនទេប្រវត្តិសេហ្នារបស់ឪពុកម្ដាយរបស់អ៊ុំ ស្រឡាញ់គ្នាយកប៉ុនដោយ។

ខ៖ ចាសគាត់ថាអញ្ចឹង! អត់មានអ្វីច្រើនទេ។ គាត់ថាគាត់ស្រឡាញ់គាត់យកប៉ុនដោយ។ ដល់ពេលអញ្ចឹងបានពីរនឹងឯង។

ក៖ ចាសចាស!

ខ៖ ចង់និយាយថា៖ ដល់ពេលដែលបានខ្ញុំពីរនឹងគាត់អស់រដូវអីចឹងហាស់?៕

ក៖ ចាសអូរ!! អញ្ចឹងបានន័យថាគាត់មានប្ដីចំណាស់ដែលហើយនឹង។

ខ៖ ចាសម៉ែរបស់ខ្ញុំអស់គាត់អាយុ ៣៨។

ក៖ ចាស!

ខ៖ អាយុ ៣៨ឆ្នាំ គាត់អស់គាត់ប្រាប់មកខ្ញុំថាអញ្ចឹងហាស់?

ក៖ ចាសមីង!

ខ៖ ហ៊ី..ម៉ែអស់រដូវអាយុ ៣៨។ ហើយបើខ្ញុំវិញអាយុ ៤៨។

ក៖ ចាស!

ខ៖ ខ្ញុំអាយុ ៤៨ឆ្នាំអស់។

ក៖ ចាស!

ខ៖ ខ្ញុំ៤៨។

ក៖ ចាសដល់ពេលមីងយូរវិញ?

ខ៖ ចាសនឹងហើយ!!

ក៖ ម្តាយរប់សមីងវិញលឿនហាស់។

ខ៖ ចាស! ម្តាយរបស់ខ្ញុំវិញគាត់ ៣៨, គាត់ប្រាប់ខ្ញុំថាហ៊ី..ម៉ែអស់យូរហើយម៉ែអស់៣៨។ គាត់អាយុ៦២ បានគាត់ខូច។

ក៖ ចាសមីង!

ខ៖ ហើយខ្ញុំ! ខ្ញុំចង់ដឹងចុះតើអាញ់ប៉ុនណា ៤៨៕

ក៖ ចាសមីង!

ខ៖ ៤៨ឆ្នាំ។

ក៖ ចាសចាស!

ខ៖ ៤៨ ខុសគ្នា១០ឆ្នាំ។

ក៖ ចាស!នឹងហើយ។ ចុះជីដូនជីតារបស់មីងវិញតើមីងមានចាំឈ្មោះរបស់ពួកគាត់ដែលឬទេ?

ខ៖ អូ ជីដីនជីតាហី?

ក៖ ចាសមីង!

ខ៖ ខាងឪពុករបស់ខ្ញុំហី?

ក៖ ចាសមីង!

ខ៖ ខាងឪពុករបស់ខ្ញុំ៖ តាប្រឹង ប៉ុន្តែត្រកូលរបស់គាត់ខ្ញុំអត់ស្គាល់ទេណាស់?

ក៖ ចាសមីង!

ខ៖ ហើយម៉ែរបស់គាត់ឈ្មោះ ៖ ម៉ែហែម។ ហើយដល់ពេលខាងម៉ែរបស់ខ្ញុំវិញឈ្មោះតាខុយ។

ក៖ ចាស!

ខ៖ ហើយម៉ែ យាយខាងម្ដាយរបស់ខ្ញុំនេះវិញឈ្មោះយាយឡាយ។

ក៖ ចាស!

ខ៖ អញ្ចឹងខ្ញុំចាំហាស់?

ក៖ ចាសមីង៕

ខ៖ គាត់និយាយប្រាប់ខ្ញុំចុះខ្ញុមធំហើយនឹង។

ក៖ ចាសមីង!

ខ៖ ខ្ញុំចាស់ហើយនឹង! ខ្ញុំអាយុមើល...! ម្ដាយរបស់ខ្ញុំខូច ខ្ញុំអាយុចាស់ដែលហើយ! នៅពេលនឹងគាត់អាយុ៨៧ឆ្នាំគាត់ខូច។ ខ្ញុំអាយុប៉ុន្មានទេ? ២០ ២០ ជាង!៕

ក៖ ២០ ជាងហើយ?

ខ៖ ចាសនឹងហើយ! ២០ ជាងហើយ។ ព្រោះអីឪពុករបស់ខ្ញុំគាត់ខូចខ្ញុំ៣០ ជាងហើយ។

ក៖ ចាសមីង!

ខ៖ ឪពុករបស់ខ្ញុំកាត់ខូច អរ...?

ក៖ គាត់ខូច ៨០ ជាង?

ខ៖ អើ! គាត់ខូច ៨០ជាងមែន។ តែគាត់ឆ្នាំ ២០០៣។

ក៖ ចាស!

ខ៖ ចាស! ឆ្នាំរ៉ែក២០០៣ នឹងហើយ។

ក៖ ចាស!

ខ៖ អញ្ចឹងខ្ញុំវាចាស់, ចាស់ច្រើនដែលហើយ!

ក៖ ចាសមីង! នឹងអញ្ចឹងពីមុខឪពុកម្ដាយរបស់មីងហាស់? អូ របស់អ៊ុំហាស់?

ខ៖ ចាស! អ៊ុំ។

ក៖ អ៊ុំ! ដោយសារតែឃើញអុះនីក្មេងច្រលំហៅតែមីងរហូត។

ខ៖ អត់ទេអ៊ុំខ្ញុំបងម៉ែក្មួយឯង។

ក៖ ចាសនឹងហើយច្រើន។ ប៉ុន្តែអ៊ុំនៅក្មេង។

ខ៖ អត់តេគ្មេងអី...! ហាហាហ..

ក៖ ចាស! អញ្ចឹងតើដូចថា ឪពុកម្ដាយរបស់អ៊ុំដូចថាបានផ្ដាំចង់អោយអ៊ុំធ្វើអីទេ?

ខ៖ គាត់អត់មានផ្ដាំអោយធ្វើអីផង. ព្រោះអ្វីអ៊ុំអត់ចេះស្អីផងអ៊ុំអត់ចេះអក្សរ អត់ចេះអីផងចេះមើលតែតិចៗ គ្រាន់មើលអក្សរដាច់បានតិចៗចឹងហាស់?

ក៖ ចាសអ៊ុំ!

ខ៖ មិនដឹងថាធ្វើស្អីបើអ៊ុំអត់ចេះធ្វើស្អីផង។

ក៖ ចាសអ៊ុំ!

ខ៖ អញ្ចឹងវា..!អត់មាន។

ក៖ អត់មានទេន៍អ៊ុំ?

ខ៖ ចាស!មានស្អីបើខ្ញុំ. បើអ៊ុំរស់នៅលើដីគេអញ្ចឹងហ្វ៕

ក៖ ចាសអ៊ុំ!

ខ៖ វាមិនអាចមានស្អីកើត។

ក៖ ចាសអ៊ុំ!

ខ៖ ចាស! នេះអ៊ុំនិយាយត្រង់ហាស់?

ក៖ ចាសចាសអ៊ុំ ខ្ញុំចង់បានការពិត។

ខ៖ និយាយអស់ពូប៉ះដូងហាស់?

ក៖ ចាសចាសអ៊ុំ។

ខ៖ ចាស! ការពិតប៉ិនដោយអត់មានលាក់លាមអីទេ។

ក៖ ចាសអ៊ុំ!

ខ៖ ចាសអត់មានលាក់លាមទេ។

ក៖ ចាសអរគុណច្រើនអ៊ុំ។

ខ៖ ចាស! ព្រោះអីអត់ចេះមែន. ដូចថាចេះអក្សរបានមើលបានតែខ្លួនឯងអញ្ចឹងហាស់។?

ក៖ ចាសអ៊ុំ!

ខ៖ ដូចថាអក្សរ រ និង ន ចឹងអានឹងឈ្មោះខ្ញុំ។

ក៖ ចាសចាសអ៊ុំ!

ខ៖ ហាហាហ...!ហើយនិយាយទៅយើងវាអត់បានរៀនយើងអត់ចេះចឹងហាស់។

ក៖ ចាសនឹងហើយអ៊ុំ!

ខ៖ ចាស! កាលនឹងអាយយុតោចដែលយួនចូលនឹង ប៉ុលពត។

ក៖ ចាស!

ខ៖ វាងត់ចេះហាស់៕

ក៖ ចាស!អញ្ចឹងពេលដែលបែកពីប៉ុលពតហើយអ៊ុំអាចរៀនបានចុះហេតិអ្វីបានជាអ៊ុំអត់រៀន?

ខ៖ អត់! បែកពីប៉ុលពតហើយខ្វមនឹកឃើញាថាខ្ជិល៕ ខ្ញុំខ្ជិលប៉ុនដោយទៅ។

ក៖ ចាស!

ខ៖ ព្រោះអ្វីយើងវាធំដែលហើយ! យើងវាចាសស់ដែលហើយ។

កៈ អូ!!!

ខៈ ទៅអត់បានរៀនទេ។

កៈ ចាស។

ខៈ តែគេអោយរៀនអក្ខរៈកម្មដែលប៉ុន្តែរៀនអត់ចេះ។

កៈ ចាសអ៊ុំ!។

ខៈ ខួរក្បាលវាម៉រចចេះបើវាចាស់ដែលហើយ។

កៈ ចាស!

ខៈ ហើយដល់ពេលទៅខ្ជិលហាស់។ គេបង្កាត់តើអក្ខរកម្មតើសាលារៀនអូរដំបងពីរយើង នេះ។ ទៅនឹងគេដែលតើ។

កៈ ចាស!

ខៈ ប៉ុន្តែរផនវាអត់ចេះ។ ហាហា...!

កៈ ចាស!ហាហា..!!

ខៈ ទៅបានមួយរយៈ ហើយអត់ចេះមែនអត់ចេះប៉ុនដោយហាស់។

កៈ ចាសមីង!

ខៈ អត់ចេះមែន៕

កៈ ចាស! អញ្ចឹងតើអ៊ុំរៀនបានដល់ថ្នាក់ទីប៉ុន្មានដែល?

ខៈ ខ្ញុំរៀនបានដល់ថ្នាក់ទី១១។

កៈ អូ!!!

ខៈ ថ្នាក់ទី១១ពីដើមហ្ស?

កៈ ចាសទី១១ ពីដើមបានន័យថា..បានទីប្រាំទីប្រាំមួយឥឡូវនេះអត់?

ខៈ អត់ទេ។

កៈ ទីមួយហើអ៊ុំ?

ខៈ អត់ទេ ទីមួយទីពីអីនឹងឯង, មិនទាន់បានចូលទីពីរល្អផង។

កៈ ចាសអ៊ុំ!

ខៈ អញ្ចឹងទៅខ្ញុំអត់ចេះទេ។

កៈ ចាស!

ខៈ ហើយដល់ពេលដែលប្រទេសរង្គុះរង្គើរអញ្ចឹងទៅដល់ពេលយើងអត់បានទៅរៀនអញ្ចឹងទៅអត់ចេះប៉ុនដោយ។

កៈ ហើយក៏អត់ម៉ងទៅន៍អ៊ុំ?

ខៈ ចាសនឹងហើយ។

កៈ ចាស! ហើយណាមួយអ៊ុំគិតថាអាយុអ៊ុំរៀងចាស់ដែលហើយក៏អត់ចូល...!

ខៈ ចាស!នឹងហើយ ដោយសារតែយើងគិតថាអាយុយើងរៀនចាស់ហើយចឹងយើងអត់បានចូលរៀនហាស់?។

កៈ ចាសអ៊ុំ!

ខៈ អញ្ចឹងទៅគេហៅអោយទៅរៀនអក្ខកម្ម,

កៈ ចាសអ៊ុំ!

ខៈ ដល់ពេលទៅរៀនអត់ចេះទៀត។ ហាហា...!

កៈ ហាហាហា..!!

ខៈ ទៅថាអូចប់បាត់ហើយអាញ់!!!

ក៖ ចាសហាហា..!!

ខ៖ ហាហា...!ទៅរៀនដែលតើអុំទៅរៀនដែឡូតើ។ នៅឈ្លាំងអូរជំបូងពីរសព្វថ្ងៃនេះ។

ក៖ ចាសអុំ!

ខ៖ ពីដើមឈ្លាំងអូរជំបងពីរហាស់។? សាលាគេអូរជំបងពីរនឹងពីដើមខ្ញុំទៅរៀននៅទីនឹងឯង។

ក៖ ចាសអុំ!

ខ៖ គេហៅឈ្លាំង, ពីប៉ុលពតគេហៅឈ្លាំង។

ក៖ ចាសអុំ!

ខ៖ ថាអត់ចេះ! ទៅគេថាអូអាញ់មិនដឹងថាបង្រៀងម៉េចទេ បើអត់ចេះសោះម៉ងចឹង។

ក៖ ចាសអុំ!

ខ៖ វាអត់ចេះមែន, អត់ចេះសោះម៉ងប៉ុនដោយ។

ក៖ ចាសអុំ!

ខ៖ ចាសអត់ចេះ។

ក៖ ចាស! តើពាក្យថាអត់ចេះមួយម៉ាត់គឺងត់ចេះប៉ុនដោយ។

ខ៖ ចាសអតចេះប៉ុនដោយ។

ក៖ ចាសអុំ!

ខ៖ ហែងមើល។ ចង់និយាយថាយើងចង់និយយាថាអក្សរអត់ចេះទេ! ប៉ុន្តែរឿងលុយរឿងអី
យើងដឹង។

ក៖ ចាសអុំ។

ខ៖ ហែងមើល,!

ក៖ ចាស!

ខ៖ គែដាក់អក្សរមកអោយយើង ៦គុណនឹង៥! ហែងគិតមើល។

ក៖ ចាស!

ខ៖ ហែលគិតមើល ៦គុណនឹង៥ វាមិន១១?

ក៖ ចាស!

ខ៖ ហើយយើងដាក់១០គត់។

ក៖ អូ ហាហាហា....!!!

ខ៖ វាចប់អាត្រង់និងឯង! វាអត់ចេះមែន។ ថាអត់ចេះមែន។ ដល់ពេលក្រោយៗយើងដឹង, យើងដឹងថាលុយយើងវាចឹង។ ដល់ពែលអក្សរវាអត់ចេះប៉ុនដោយហែងមើល..!!

ក៖ ចាសអុំ!

ខ៖ អត់ចេះទេ! អូបើអញ្ចឹងមិនបាច់មករៀនទេ។

ក៖ ចាស!

ខ៖ ខ្ញុំថាមិនចេះទេមិនចេះទេ។

ក៖ ហាហាហា..!

ខ៖ ទៅរៀនអក្ខកម្មបានមួយសន្ទុះដែលតែថាអត់ចេះទេ អត់ចេះទេ។ អត់ចេះមែនប៉ុនដោយ។

ក៖ ហាហាចាស!!

ខ៖ អត់ចេះ! អត់ចេះគ្រូថាអូ..! មិនដឹងថាមករៀនធ្វើអីទេហាស។

ក៖ គ្រូខ្ចិលបង្រៀងដែលពេលនឹង?

ខ៖ គ្រូខ្ចិលបង្រៀនចុះបើអត់ចេះមែនហ្ញ!!

ក៖ ចាស!

ខ៖ ចាស! ហៃលមើល ៦បូកនឹងប្រាំដាក់ ១០គត់!?

ក៖ ១០ គត់? ហាហាហ...!!!

ខ៖ គ្រូគាត់ថាអូរ..អាញ់ចប់ប៉ុនដោយ..។

ក៖ ៦ បូក ៥ គត់។ ហាហាហ..!

ខ៖ អើ!! ៦ បូក ៥ ដាក់ ១០គត់ហៃលមើលមានដែល? ហាហាហស...! ចប់ ចាំរហូតដល់សព្វថ្ងៃនេះ។ ចាំ ចងចាំអាពាក្យមួយនឹងរហូតមកដល់សព្វថ្ងៃ។

ក៖ ចាស! អ៊ុំ សាហាវបូកលេខណាស់!!

ខ៖ ចាសនឹងហើយ!

ក៖ ចាស៥បូកនឹង៥១០គត់។

ខ៖ ចាសនឹងហើយ១០គត់។ ហៃលមើលដល់ហើយចប់។

ក៖ ចាសហាហា!

ខ៖ ដល់ពេលចឹងមិនបាច់ទេហា។ មិនដឹងថាមករៀនធ្វើអ្វីទេ។ ហើយថាបើអត់ចេះអត់ចេះហើយនឹងនៅតែអោយមករៀនទៀត។

ក៖ ចាស។

ខ៖ ចាសហាហា!

ក៖ ចាស! តែបើសិនជាអ៊ុំតស៊ូនៅរៀនតើអ៊ុំគិតថាអ៊ុំអាចនឹងរៀនចេះដែលឬអត់?

ខ៖ កាលនឹងប្រហែលជាចេះច្រើនជាងនឹង។ តែនឹកឃើញថាខ្ជិលហូ..?

ក៖ ចាស!

ខ៖ ចុះបើគ្រូថា: អាញ់មិនដឹថម៉េខទេហា..!

ក៖ បើ ៦បូកនឹង៥១០គត់៕

ខ៖ ចាស! ថាចឹងឯងកាលនឹង។ ហើយឡើងក្ដារខៀនទៀតណាស់។

ក៖ ចាស!

ខ៖ ៥បូកនិង៥ ១០គត់។

ក៖ ចាសអុំ!

ខ៖ សរសេរអក្សរលេខមួយហើយនឹងលេខសូន្យ។ ចាស! ចប់បាត់ហើយគ្រូថាងាប់ហើយអាញ់ងើយអាញ់...!!

ក៖ ហាហាហា..! ១០គត់មែន!!!

ខ៖ ១០គត់មែន។ អញ្ចឹងមិនបាច់រៀនទេ។

ក៖ ចាសហាហា...!

ខ៖ ដល់ពេលអញ្ចឹងក៏ខ្ជិលទៅ, ហើយថាចាក់ថាមិនចេះមិនចេះហើយនៅអោយមករៀនទៀត។ ហាហាហាស...!!!!

ក៖ ហាហាចាស!

ខ៖ ប្រកែកជាមួយគ្រូចឹងហាស់៕ ថាមិនចេះមិនចេះហើយនៅតែអោយមករៀនអាញ់ស្អប់ណាស់។

ក៖ ចាសអុំ!

ខ៖ ថាមិនចេះមិនចេះមិនចេះហើយ។

ក៖ អូ!!!! ហាហា..

ខ៖ ហាហា!!

ក៖ ចាស!

ខ៖ ខ្មោចរបស់ឪពុកខ្ញុំគាត់ថាចាក់, អូកូនអាញ់ឯកាតាំងពីប៉ុលពត។ ឪពុករបស់ខ្ញុំគាត់ថាកូនអាញ់អត់ចេះទេ។ ហើយចុះខ្ញុំប្រាប់ហើយនឹងមិនជឿ។

ក៖ ឯត់ជឿ?

ខ៖ អត់ជឿ! ចាមិនចេះមិនចេះហើយនឹង, មិនចេះមែនរហូតមកដល់ឥឡូវ។

ក៖ ចាសអ៊ុំ! នឹងហើយអ៊ុំ។ អញ្ចឹងតើអ៊ុំមានដាច់ញាត្តិឬក៏បងប្អូនណាដែលពួកគាត់នៅក្រៅប្រទេសដែលរទេឬក៏នៅឆ្លងខេត្ត?

ខ៖ អ!! មាន, តែមានតែកូនម៉ែរបស់ខ្ញុំ។

ក៖ ចាស!

ខ៖ មិនមែណកូនរបស់ឪពុកខ្ញុំទេណាស់ជាកូនរបស់ម៉ែរបស់ខ្ញុំ។

ក៖ ចាសអ៊ុំ!

ខ៖ ម៉ែរបស់ខ្ញុំគាត់បានប្ដីពីរអញ្ចឹងហាស់?

ក៖ អូចាស!

ខ៖ គាត់មាន!

ក៖ ចាស! អញ្ចឹងតើគាត់នៅណាដែល?

ខ៖ គាត់នៅ! អ..? កាលីហ្វូញ៉ា៕

ក៖ អូ!! តើពួកគាត់ដែលទាក់ទងមកលែងអ៊ុំដែលឬទេ?

ខ៖ ទាក់ទង។ ប៉ុន្តែរៀងបាត់យូរដែលហើយ។

ក៖ ចាស!

ខ៖ អត់ឃើញគេទាំក់ទងមកលែងទៀតទេ។

ក៖ ចាស! គាត់ត្រូវជាសាច់ញាត្តិខាងឪពុក?

ខ៖ អត់ទេខាងម្ដាយ៕

ក៖ ខាងម្ដាយ។

ខ៖ ចង់និយាយថាប្ដីមុន។

ក៖ ចាសប្ដីមុនប្ដីមុន។

ខ៖ អើ!!

ក៖ ចាស!

ខ៖ មាន!

ក៖ ចាស! អញ្ចឹងតើគាត់មានដែលអោយអ្វីដល់អ៊ុំទេ?

ខ៖ អោយដែលតើ! ប៉ុន្តែយូរៗម្ដង។

ក៖ ចាស!

ខ៖ អញ្ចឹងហាស់?

ក៖ ចាស!

ខ៖ គាត់ជួយចិញ្ចឹមហាស់។ ម្ដងៗប៉ុន្តែគាត់អត់មាននរណាទេ។ គាត់អត់ចេះអក្សរដែលនឹង។

ក៖ អូចាស!

ខ៖ ចាស! គាត់អត់ចេះអក្សរដូចគ្នា។

ក៖ អញ្ចឹងតើគាត់នៅទៅនោះតើកាត់ធ្វើការអ្វីដែលអត់?

ខ៖ អត់! អត់។ ស៊ីប្រាក់ខែជំចង្ហឺហាស់។

ក៖ អូ តើគាត់ឈឺហីអ៊ុំ?

ខ៖ ចាស! គាត់ឈឺ។

កៈ តើគាត់ឈឺអ្វីដែល?

ខៈ គាតោ់ខ្សោយក្រលានទឹកនោមផ្អែកហើយនៅស្អីៗទៀត, អូគាត់ឈឺច្រើនមុខហាស់។

កៈ ចាសអ៊ុ! សុទតែរោគអ្នកមាន។

ខៈ ចាសអញ្ចឹងហើយបានជាគាត់អត់មានស្អីជួយផ្គត់ផ្គន់យើងហាស់?

កៈ ចាស!! ឈឺច្រើនពេក។

ខៈ ចាស! និយាយទៅវាអាណិតគាត់ដែលប៉ុន្តែមិនដឹថាធញរើម៉ែច។

កៈ ចាស! ដោយសារ..?

ខៈ ហើយគាត់មេម៉ាយហាស់?

កៈ ចាស!អូចាស គាត់មេម៉ាយ?

ខៈ ចាស!គាត់មេម៉ាយ។

កៈ ហុឹម...អញ្ចឹងពិបាកហើយអញ្ចឹងហូ។

ខៈ ចាស!

កៈ ប៉ុន្តែគាត់សំណាងដែលគាត់នៅទីនោះបានដួគេចិញ្ចឹមហូ, តែបើនៅស្រុកខ្មែរប្រហែលជាគាត់ទៅបាត់យូរហើយ។

ខៈ ចាសចាស! អត់ទេបើនៅខ្មែរគាត់ងាប់បាត់យូរហើយ។

កៈ ចាសអ៊ុំ!

ខៈ ព្រោះអីរោគគាត់វាច្រើនមុខពេក។

កៈ ចាស! ហើយគាត់ធ្វើម៉ែចបានបានទៅនៅស្រុកគេ? ហើយអ៊ុំនៅខ្មែរ?

ខៈ ខ្ញុំ! គាត់ទៅជំរុំហើយខ្ញុំអត់បានទៅ។

កៈ អូ!!!

ខៈ ចាស! គេយកទៅជំរុំហាស់? ជំរុំយើងហាស់?

កៈ នឹង!

ខៈ ជំរុំយើងហាស់?

កៈ ចាស!

ខៈ តែអុំអត់, អុំអត់បានទៅ។ អុំអត់បានទៅអុំនៅខ្មែររួចក៏អុំនៅខ្មែរប៉ុនដោយ។

កៈ ចាសអុំ!

ខៈ គាត់ទៅជំរុំគែដឹកគាត់យកទៅអញ្ចឹងហាស់?

កៈ ចាស! អញ្ចឹង។ ឥឡូវសួរដល់ប៉ុលពតវិញ។

ខៈ ចាស!

កៈ អញ្ចឹងប៉ុលពតអុំកើតតានមែនដែលអត់៕?

ខៈ ចាស!

កៈ អញ្ចឹងកាលដែលអុំកើតទាន់នឹងតើអុំមានអាយុប៉ុន្មានឆ្នាំដែល?

ខៈ ខ្ញុំមានអាយុ១២ឆ្នាំហើយ។

កៈ អូ! អុំធំដឹងក្តីហើយ។

ខៈ ចាស! ដឹងតើដឹង។

កៈ ចាស!

ខៈ ចាស!

កៈ អញ្ចឹងតើកាលណឹងគេអោយអុមធ្វើអ្វីដែលការងារ?

ខ៖ អុំហ្ង!? គេអោយអុំរ៉ែកដី, រ៉ែកដីបង្គីប៉ុនៗនេះ។

ក៖ អូ!! តូចៗៗ?

ខ៖ ហ៊ី!! ចាស!ប៉ុនៗនេះ។

ក៖ ចាស! ហើយរ៉ែកដាក់ណាដែល?

ខ៖ រ៉ែកដាក់កំពឹងពួងសព្វថ្ងៃ។

ក៖ ចាស! ពីណាទៅណាដែល?

ខ៖ ទៅកំពឹងពួយ។ អត់ទេរ៉ែកពីក្រោមអញ្ចឹងមករ៉ែកដាក់។

ក៖ អូ!! រ៉ែកដាក់ទំនប់ហីអុំ?

ខ៖ ចាសទំនប់មគពឹងពួយសព្វថ្ងៃនេះ។

ក៖ អូចាស! អញ្ចឹងទំនប់សព្វថ្ងៃនឹងអុំជាអ្នកធ្វើ?

ខ៖ ចង់និយាយថា..!

ក៖ ធ្វើជាមួយគេជាមួយឯង?

ខ៖ ចាស! ជាមួយគេ។ គេធំៗគាំតធ្វើមុនហាស់?

ក៖ ប៉ុន្តែយើងក្រោយយើងលើកទៅ

ក៖ ចាស!

ខ៖ ចាស!

ក៖ អ៊ូ!!! អញ្ចឹងទំនប់នឹងតាំងពីអើយមក?

ខ៖ ចាសនឹងហើយ!

ក៖ តាំងពីរជំនាន់នឹងមក។

ខ៖ ចាសចាស!

ក៖ ប៉ុលពតជាអ្នកធ្វើបើនិយាយទៅ។

ខ៖ ចាស! នឹងហើយនឹងហើយ។

ក៖ ចាស! អញ្ចឹងតើអ៊ុំគិតយ៉ាងម៉េចដែលពីជីវិតរបស់អ៊ុំនៅពេលនឹងវាពិបាកម៉ែចដែលអ៊ុំរ៉ៃរ៉ាប់ប្រាប់ខ្ញុំបន្តិចមក?

ខ៖ កាលនឹងវា! អញ្ចឹងឯង, ធម្មតាទេយើងនីក្មេងយើងនៅខ្ចីនៅតូចអញ្ចឹងរ៉ែកឡើង។

ក៖ ចាស!

ខ៖ រ៉ែកឡើងទៅ, ដាក់ទៅ ហើយកាលនឹងក្នុងមួយនាកើគេអោយរ៉ែកបានមួយម្រ៉ែតគីប។

ក៖ មួយម្រ៉ែតគីបហ្អ៊ុំ។

ខ៖ ចាស!មួយម្រ៉ែតចេះ ហើយជំរៅ។

ក៖ អូ!!! ចាស!

ខ៖ ចាសមួយតឲយប់មួយថ្ងៃហាស់?

ក៖ ចាសអ៊ុំ!

ខ៖ យើនៅក្មេងយើងនៅតូវចឹងហាស់។

ក៖ ចាស!

ខ៖ អញ្ចឹងគេអោយអញ្ចឹងយើងលើកទៅ។

ក៖ ចាស!

ខ៖ ចាស! ដល់ណពេលក្រោយមកទំនប់នឹងបានគេឈប់អោយធ្វើអញ្ចឹងយើងមកផ្ទះវិញមកហាស់៕

ក៖ ចាសអ៊ុំ!

ខ៖ មកផ្ទះវិញទៅ! ប៉ុន្តែមិនមែនមកវិញស្រួយទេណាស់៕?

ក៖ ចាស!

ខ៖ អ៊ុំឈឺហាស់! មកវិញឡោះងរុសសក់។

ក៖ អូ!!! តើអ៊ុំឈឺអ្វីដែលកាលណឹង?

ខ៖ កាលនឹងចាញ់៕

ក៖ គ្រុនចាញ់មែនអ៊ុំ?

ខ៖ គ្រុនចាញ់នៅកំពីងពួយនឹងឯង។

ក៖ អូ!!!

ខ៖ គេដឹកយកមកដកពេទ្យវត្តតាមិមសព្វថ្ងៃនេះ។ សាលារៀន។

ក៖ ចាសអ៊ុំ!

ខ៖ សព្វថ្ងៃនេះសាលាវត្តតាមិមនេះឯង។

ក៖ ចាសអ៊ុំ!

ខ៖ មកដេកពេទ្យនឹងឯងដល់ពេលផុតបានឡើងយូរបានមកដេកពេទ្យនៅអូខ្វាយ។

ក៖ ចាសអ៊ុំ!

ខ៖ ហើយកាលនឹងរុះសក់អស់ហើយ។

ក៖ ចាសហ៊ី!!!

ខ៖ ដល់ពេលទៅបងប្រុសមួយទៀតនឹងឯង។ ដល់ពេលគាត់ឃើញទៅគាត់អាណិតទៅទៅសុំដល់នីរតីអញ្ចឹង, គាត់សុំខ្ញុំយកទៅពេទ្យ។

ក៖ ចាសអ៊ុំ!

ខ៖ យកខ្ញុំទៅពេទ្យទៅផ្ទះនៅអូរសោឡេហាស់?

ក៖ ចាស!!

ខ៖ យកទៅផ្ទះនៅអូរសោឡេ, ពុកម៉ែរបស់ខ្ញុំនៅអូរសោឡេ។

ក៖ ចាសចាស!

ខ៖ ទៅ! ដល់ពេល។ ប្រឹសៗបានបន្តិចយួនចូល។

ក៖យួនចូល?

ខ៖ ចាស!គ្មានបាន, រត់មកគ្មានយកអ្វីបានទេ។

ក៖ ចាស!

ខ៖ ហើយកាន់តែហិបស្លាម៉ែមួយនឹងកាន់មិនចង់កើតផង។

ក៖ ចាសអ៊ុំ!

ខ៖ ចុះបើវាអស់មែនទែនហើយ!

ក៖ ចាសអស់កម្លាំង។

ខ៖ វាអស់កំម្លាំង, វាឈឺហូ!!? កាលនឹងរត់រហូត រត់រហូតមកដល់ ដល់មកនៅនៅផ្ទះដីសព្វថ្ងៃនឹងហាស់?

ក៖ ចាសអ៊ុំ!

ខ៖ ដល់ពេលអញ្ចឹងទៅសុំគេនៅនឹងប៉ុនដោយទៅ។

ក៖ ចាសអ៊ុំ!

ខ៖ ចាសនៅនឹងឯង! រហូតបានមកដល់សព្វថ្ងៃនឹងហាស់។?

ក៖ ចាស.!

ខ៖ អញ្ចឹងបានជាគេអោយនៅមាយើងងាប់អញ្ចឹងហាស់?

ក៖ ចាស! ហាហាហា...!!

ខ៖ ហាហា!! អោយមាងាប់និយាយមែន។ អោយនៅមារស់អញ្ចឹងហាស់។ ដល់ពេលងាប់គេយលវិញទៅ។ ហើយនៅដល់សព្វថ្ងៃទៅ។

ក៖ ចាសអ៊ុំ!

ខ៖ ហើយដល់ពេលភូមិឃុំកេឃើញយើងនៅតាំងតែពីឆ្នាំ១៩៧៩អញ្ចឹងហាស់? គេទៅវាស់ដីអោយ។

ក៖ ចាសអ៊ុំ!

ខ៖ ហែងដាំប៉ុនណាហ់យធ្វើប៉ុនណាអញ្ចឹងហាស់គេវាស់អោយ។

ក៖ ចាស!

ខ៖ ហើយខ្ញុំក៏ថាខ្ញុំអត់ទេ។ ខ្ញុំអត់មានអីទេ, ខ្ញុំមកអត់មានយកអីបានផងនឹង។

ក៖ ចាស!

ខ៖ អញ្ចឹងម៉ែរបស់ខ្ញុំមកសុំគេនៅសោះ។

ក៖ ចាស!

ខ៖ អញ្ចឹងយើងមិនអាចយកបានទេ។

ក៖ ចាស!

ខ៖ អញ្ចឹងខ្ញុំអត់យកទេ! អត់យករហូតមកដល់សព្វថ្ងៃនឹង។ ខ្ញុំអត់យកទេ។

ក៖ ចាសអ៊ុំ!

ខ៖ ទៅពួកគេថា, ចុមគេយកអស់ហើយអត់តែនាងនឹងមួយអត់យក។

ក៖ ចាសហាហាស...!!

ខ៖ ខ្ញុំថាអតយកទេ។ សុំតែមួយរស់។

ក៖ ចាសអ៊ុំ! បើនិយាយទៅមិនដឹងថាយកទៅបានស្អីផង។ បើយើងយើងយកទៅមានតែលក់យកលុយចាយ។

ខ៖ ចាស!

ក៖ ហើយបើលក់ទៅចាយលុយអស់ដដែល។

ខ៖ នឹងហើយ។

ក៖ ចាស! ហើយបើយើងនៅជាមួយគេ, បានគេអាណិតអីទៅ។

ខ៖ ចាសបានគេអាណិតយើងគេស្រណោះយើង។

ក៖ ចាសនឹងហើយអ៊ុំ។

ខ៖ ចាស!

ក៖ ចាស! អ៊ុំគិតអញ្ចឹងត្រូវហើយ។

ខ៖ ចាស! ខ្ញុំអត់ចង់បានអ្វីជារបស់គេព្រោះអ្វីខ្ញុំចង់និយាយថាព្រោះអីខ្ញុំកើតមកក៏អត់មានបានយកអីមក, ហើយទោះបីជាខ្ញុំស្លាប់ទីវិញក៏ខ្ញុំទូលយកទៅវិញអត់កើតដូចគ្នា។

ក៖ ចាសនឹងហើយអ៊ុំ។

ខ៖ ខ្ញុំចង់និយាយថាអញ្ចឹងហះ?

ក៖ ចាស!

ខ៖ នឹងហើយ! ខ្ញុំនិយាយមែន។ ដល់ពេលអញ្ចឹងទៅខ្ញុំខ្ចិលហាស់។ ខ្ញុំក៏ថាអត់យកទៅ។ ហើយកាលដែលគេមកនិយាយនឹង, កាលនឹងឪពុករបស់ខ្ញុំគាត់នៅរស់ទេណាស់?

ក៖ ចាសអ៊ុំ

ខ៖ ចាស!! ឡើងទៅនិយាយជាមួយឪពុកនៅលើផ្ទះហើយភៀវនៅក្រោម។

កៈ ចាស!

ខៈ ហើយទៅអរ!! ដល់ពេលរួចរួចទៅគាត់ថាចាក់, ហ៊ឹម...! ខ្ញុំមិនយូរមិនឆាប់ទេ, ព្រោះអ្វីខ្ញុំចាស់ហើយហាស់?

កៈ ចាស!

ខៈ ឪពុកខ្ញុំគាត់ក៏ថាទៅសួរកូនរបសខ្ញ។មើល, បើកូនខ្ញុំគេគិតម៉ែចគិតអញ្ចឹងទៅ។

កៈ ចាសអ៊ុំ!

ខៈ គាត់អត់មានគិត។គាត់ចង់និយាយថា!គាត់ជាអ្នកសុំគេនៅ។ ចុះកាលនឹងខ្ញ។នៅតូចៗហ្ន?

កៈ ចាសអ៊ុំ

ខៈ អើ!! អញ្ចឹងអោយសួរកូនខ្ញុំទៅ,បើវាចង់បានអោយវាគិតគូរខ្លួនវាទៅ។ ដល់ពេលរឿងគាត់មួយវាដាប់ដោយឡែកហើយណាស់៕

កៈ ចាសអ៊ុំ។

ខៈ ហើទៅក៏គាត់ចុះមកុំ ហែងយកដីអត់មាវាស់អោយ។

កៈ ចាសអ៊ុំ!

ខៈ ខ្ញុំហៅគាត់មាហាស់?

កៈ ចាសអ៊ុំ!

ខៈ អញ្ចឹងខ្ញុំក៏ថាខ្ញុំអត់យកទេ។

កៈ ចាសអ៊ុំ!

ខៈ ពុកម៉ែរបស់ខ្ញុំសូមគេតែមួយនៅនឹង។ ហើយពុកម៉ែរបស់ខ្ញុំដុតនៅនឹងដីរបស់គែទៀតណាស់កាលណឹង។

កៈ ចាស!

ខ៖ ដុតហាស់!ជិតនៅនឹងដីទៀត។

ក៖ ចាសអ៊ុំ។

ខ៖ អញ្ចឹងហើយបានថាខ្ញុំត់អាចយកដីរបស់គេបានទេ។

ក៖ ចាស!

ខ៖ អញ្ចឹងខ្ញុំសូមតែមួយរស់ទៅចុះ។

ក៖ ចាសអ៊ុំ!

ខ៖ ស្រណុកម៉េចម៉ាអីអោយគេយកទៅវិញទៅណាស់?

ក៖ ចាសអ៊ុំ!

ខ៖ ហើយអោយគរវាស់ទៅ, ហើយផ្ទះ ជាផ្ទះរបស់ខ្ញុំមែនប៉ុន្តែដីជាដីរបស់គេ។

ក៖ ហ៊ឺ!!! ចាសយ់ងមានតែផ្ទះទេ?

ខ៖ ចាស!យើងមានតែផ្ទះមួយហើយនឹងផ្ទះបាយមួយ។

ក៖ ចាសអ៊ុំ!

ខ៖ កុំនិយាយបាប។

ក៖ ចាស!

ខ៖ ចាស! អញ្ចឹងរឿងនឹងវាអញ្ចឹងឯង។ ខ្ញុំអត់និយាយកុហក់ទេ។

ក៖ ចាសអ៊ុំ!

ខ៖ ខ្ញុំនិយាយត្រង់ហានឹងហានិយាយដោយអស់ពីចិត្ត។

ក៖ ចាសអ៊ុំចាស! អរគុណអ៊ុំច្រើនអ៊ុំ។

ខ៖ ចាសចា!

កះ ចាស! អញ្ចឹងកាលណឹងគេប្រើអ៊ុំអោយជីកដីមួយម្រ៉ែតបួនជ្រុងចឹងហាស់។

ខះ ចាសចា!

កះ អញ្ចឹងកាលណឹងអ៊ុំមានអាយុ១២១៣ទៀត។

ខះ ចាស!១២ ១៣ អីនឹងឯង។

កះ ចាស! អញ្ចឹងតើអ៊ុំគិតថាជីវិតរបស់អ៊ុំនៅពេលនឹងគឺពិបាកដើម្បីមនឹងឆ្លងកាត់ដែលឬអត់?

ខះ ចាសពិបាក ពិបាកដម្បីឆ្លងកាត់។ ពិបាកនឹងឯង, កាលនឹងយើងនៅតូច ហើយគេអោយរ៉ែកហើយយើងចេះតែរ៉ែកតាមគេប្រើយើងទៅ។

កះ ចាសអ៊ុំ!

ខះ ទាំងយប់ទាំងថ្ងៃហាស់?

កះ អូ!! ធ្វើទាំងយប់ទៀត?

ខះ ចាស!

កះ អញ្ចឹងតើគេអោយអ៊ុំសំរាកប៉ុន្មានម៉ោង?

ខះ សំរាក!មើល, ពីម៉ោង ប្រាំពីរ ដល់ម៉ោង ១១។ យើងសំរាកបាន…ហើយម៉ោងមួយចុះទៀត។

កះ ចាសអ៊ុំ!

ខះ ហើយម៉ោងប្រាំគេអោយឈប់, ហើយងូតទឹកងូតអីហើយដល់ម៉ោង ៧យប់ ឯដល់យប់ចុះទៀត, ចុះហើយម៉ោង១១យប់បានបានយើងចេញ។

កះ ចាស!

ខះ មកគែងវិញ។

កះ ចាសអ៊ុំ!

ខ៖ នឹងហើយគិតមើលទៅទៀត។

ក៖ ចាស!

ខ៖ អញ្ចឹងហាស! តែធម្មតាទេយើងនៅតូចគេមិនទៅអោយយើងធ្វើអីច្រើន។ រែកដីមួយបង្គី ប៉ុននឹងឯង។

ក៖ ចាស!

ខ៖ ហើយចេះតែតៀតៗតាមគេទៅ។

ក៖ ចេះតែតាមគេទៅន៏អ៊ុំ?

ខ៖ ចាស!តៀតៗតាមគេទៅ។ តាមគៃទៅ, បើសិនជាយើងើមិនធ្វើវាមិនកើត អញ្ចឹងយើងត្រូវ តែធញរើអញ្ចឹងហាស។

ក៖ ចាសអ៊ុំ!

ខ៖ ដល់ពេលអញ្ចឹងយើងចេះតែធ្វើទៅ។

ក៖ ចាស!

ខ៖ អញ្ចឹងឯង។

ក៖ ចាស! អ៊ុំហាសដោយសារតែអ៊ុំនៅក្មេងហាស?

ខ៖ !ចាស!

ក៖ តើអ៊ុំឆ្លងកាត់យ៉ាងម៉េចបានដើម្បីយើងឈ្នះនៅឧបស័គ្គមួយនឹងហាស?

ខ៖ ចាស!

ក៖ ដោយសារតែយើងចង់គេចទៅណាក៏គេចមិនកើតដោយសារយើងរស់នៅក្នុងការគ្រប់គ្រង របស់គេ៕

ខ៖ ចាសចាស!

កៈ ចាស!ចុះអ៊ុំ! បានឆ្លងកាត់វាបានដោយរប្រៀបណាហើយតស៊ូវាបានដោយរប្រៀបណាតើអ៊ុំអាចចែកចាយជាមួយនឹងខ្ញុំតើបានទេ?

ខៈ ហ៊ឺ..ចុះអញ្ចឹងឯង។ យើងចេះតែខំពុះពារធ្វើយ៉ាងម៉េចក៏ដោយដើម្បីរស់ហាស់?

កៈ ចាស!

ខៈ ធ្វើទៅរហូតដល់ខ្ញុំឈឺគឺដឹកខ្ញុំមក។

កៈ ចាស!

ខៈ ហើយរហូតដល់....មកនៅជាមួយឪពុកម្ដាយរបស់ខ្ញុំវិញបានប្រឹសៗបន្តិចនឹងយួនចូល។

កៈ ចាស! យួនចូលមក។

ខៈ ចាស ចាស! ហើយខ្ញុំមកមិនបានយកអ្វីមកជាមួយទេ, គ្រាន់តែលើកកន្ត្រាំងស្លាអោយម្ដាយ។, ហើយគាត់ជាអ្នកទូលទៅ ហើយឪពុកខ្ញុំគាត់រ៉ែកទៅ ហើយបងប្រុសខ្ញុំប្ដីពៅទ្យលីនឹងគាំត់រ៉ែកដែលទៅ។

កៈ ចាស!

ខៈ ហើយខ្ញុំរត់តាំងៗតាមម្ដាយទៅ។

កៈ ចាស!

ខៈ ចុះបើខ្ញុំឈឺហ្ស!!!

កៈ ចាសអ៊ុំ!

ខៈ ហើយមានទៅកាន់អ្វីកើត។ សូម្បីតែខោអាវខ្លួនឯងមួយកំផ្លេក៏កាន់មកកើតផង, បានតែកាន់កាន្ត្រាំងស្លារបស់ម្ដាយខ្ញុំមួយតែប៉ុននឹងឯង។

កៈ ចាសនឹងហើយអ៊ុំ!

ខៈ ចាស!វាឆ្លងកាត់អញ្ចឹងឯង។

កៈ ចាសអ៊ុំ! អញ្ចឹងឪពុកម្ដាយរបស់អ៊ុំនៅកាលណឹងគាត់ធ្វើទូនារីហើយកាន់ខាងផ្នែកអ្វីដែល?

ខៈ គាត់អត់, គាត់អត់មានធ្វើអ្វីផង! គាត់ធ្វើ! បើនិយាយទៅកាលពីប៉ុលពតនឹង...គាំត់អត់មានធ្វើអីផង។ គាត់គេអោយតែធ្វើចំការហើយគេអោយគាត់ធ្វើអ្វីគាត់ធ្វើតាមតែចឹងទៅណាស់?

កៈ ចាសអ៊ុំ!

ខៈ ចាស!

កៈ ចាស! ខ្ញុំស្មានតែគាត់ធ្វើជាអ្នកដឹកនាំកងចល័តកងអីចឹងហាស់?

ខៈ អត់ទេ! ពួកគាត់ចាស់ៗអស់ហើយទៅធ្វើស្អី។ ធ្វើអត់កើត។

កៈ ចាសនឹង! អញ្ចឹងដោយសារតែអ៊ុំបានចូលរៀនដែលតែអ៊ុំរៀនអត់ចេះទេ?

ខៈ ចាស!

កៈ ចាស! អញ្ចឹងខ្ញុំបានសួរអ៊ុំហើយៗ។ អញ្ចឹងអ៊ុំកើតមករហូតដល់ធំនឹងអញ្ចឹងគ្រុមគ្រួសាររបស់អ៊ុំជាអ្នកស្រែចគការម៉េងឬក៏ម៉េចដែលអ៊ុំ?

ខៈ ចាស! ជាអ្នស្រែចំការ។

កៈ អញ្ចឹងមកពេលឥឡូវនេះតើអ៊ុំមានស្រែចំការធ្វើទៀតដែលឬអត់?

ខៈ អូចាស! ខ្ញុំអត់មានទេ។

កៈ ចាស! អត់មានទេ។

ខៈ ចាស!

កៈ អញ្ចឹងតាំងពីធំដឹងក្ដីរហូតមកដល់ប៉ុនេះតើអ៊ុំបានធ្វើការងារអ្វីខ្លះដែឡអ៊ុំ?

ខៈ អត់! អ៊ុំអត់បានធ្វើអីផង។

កៈ អញ្ចឹងអ៊ុំនៅតែផ្ទះសុទម៉ង?

ខៈ នៅផ្ទះអត់ទេ! ពេលគេអោយយើងលាងចានលាងឆ្នាំង, គេធ្វើចុងភៅហ្វ?

កៈ អូចាស!

ខៈ គែអោយយើងទៅលាងចានអោយគេ។

កៈ ហ៊ឺ!!!!

ខៈ ហើយឥឡូវនេះអ៊ុំទៅធ្វើការអោយគេលែងកើតហើយ។

កៈ ចាស!

ខៈ ចង្កុះអ៊ុំ។

កៈ ឈឺហូអ៊ុំ?

ខៈ ចាស! ចង្កុះឈឺជង្គន់ឈឺ។

កៈ ចាស!ៗ

ខៈ ថ្ងៃណាទៅជាប់, ជាប់ជង្គន់ហើយនឹងចង្កុះ។ ធ្វើអោយគែអត់កើតទេ។ ហើយសព្វថ្ងៃនេះ ទោះបីជាគែហៅក៏ធញជើអោយគេលែងរួតដែល។

កៈ ចាសហ៊ឺ!!!!

ខៈ បើលើកមុនធ្វើមែន។ ឥឡូវនេះធ្វើអោយគែមិនកើតទេ, ធ្វើអោយគេមិនកើតប៉ុនដោយ។

កៈ ចាស! អញ្ចឹងអ៊ុំចាប់ផ្តើមធ្វើការអោយគែលែងកើតអោយគែនឹងតើអស់រយៈពេលប៉ុន្មានឆ្នាំ ដែលហើយ?

ខៈ អត់ទេ ទឹមតែឆ្នាំនេះឯង។

កៈ អូ!! ឆ្នាំនេះម៉ងហីអ៊ុំ?ល

ខៈ ចាស! ឆ្នាំនេះ ៥៧នឹងធ្វើលែងកើតប៉ុនដោយ។

កៈ ចាសអ៊ុំ!

ខៈ វាឈឺហាស់។ ដល់ពែលឈឺធ្វើអត់កើតចឹងឈប់ប៉ុនដោយ។

កៈ ចាសអ៊ុំ។

ខៈ ខ្វិលហាស។

កៈ នឹងហើយអ៊ុំ។

ខៈ ចាស!

កៈ អញ្ចឹងអ៊ុំហាស់? តាំងពីដឹងក្តីមកហើយអ៊ុំមានក្តីស្រម៉ៃថាអ៊ុំចង់ធ្វើអ្វីទៃពេលដែលអ៊ុំធំឡើង?

ខៈ និយាយទៅវាមិនដឹងថាធ្វើស្អីបើយើងអត់ចេះអក្សរចឹងហ្។

កៈ ចាស! តែអ៊ុំចង់ធ្វើអីដែលឬអត់ទោះបីជាអ៊ុំអត់ចេះអក្សរក៏ដោយហាស?

ខៈ មិននឹងស្មានថាចង់ចេះធ្វើស្អីទេក្មួយបើអត់ចេះស្អីសោះប៉ុនដោយ។

កៈ ចាស! ហើយអត់ចង់ធ្វើអ្វីទៀតន៍?

ខៈ បើអត់ចេះចឹង។ ចង់និយាយថាគេត្រូវការអ្នកដៃឡចេះអក្សរ។

កៈ ចាស!

ខៈ អញ្ចឹងបើយើងអត់ចេះអញ្ចឹងមិនដឹងថាចង់ទប្រថ្នាយ៉ាងម៉េចទេក្មួយ។

កៈ ចាស!

ខៈ និយាយមែននេះនិយាយត្រង់ប៉ុនដោយហាស។

កៈ ចាសចាសអ៊ុំ!

ខៈ ចង់អោយទៅធ្វើយ៉ាងម៉េចបើអត់ចេះអក្សរចឹង, គេត្រូវការចេះ ហើយយើងអត់ចេះអញ្ចឹង ហើយទៅធ្វើតាមដំណើរទៅ។ តាមដំណើរ..!

កៈ ចាសអ៊ុំ! តើអ៊ុំមានការស្តាយក្រោយដៃឡឬអត់ដោយសារតែ....?

ខៈ ស្តាយ ស្តាយតើ។

កៈ ស្ដាយន៏អ៊ុំ?

ខៈ ចាស! ចុះធ្វើម៉ែចបើយើងអត់ចេះ វាអតចេះមែន។

កៈ ចាស!

ខៈ ដល់ពេល..ចង់និយាយយើងចង់វាលែងចេះវាអត់កើតប៉ុនដោយហាស់។ តាមដំណើរទៅ

កៈ ចាស! ទៅលែងរួតហើយ។

ខៈ ទៅលែងរួចហើយចាស

កៈ ចាសលខ្ខណៈថា ហួសពេលហើយ។

ខៈ ចាសហួសពេលហើយ។

កៈ ចាស! អញ្ចឹងជីវិតរបស់អ៊ុំបើប្រៀបធ្រៀបទៅនឹងជីវិតពីមុនតើខុសគ្នាច្រើនដែលឬអត់?

ខៈ ចាស!

កៈ តើខុសគ្នាបែបណាខ្លះ?

ខៈ កាលពីនៅម៉េច?

កៈ កាលពីនៅជាមួយគ្រួសារ។

ខៈ អូ!! នៅជាមួយឳពុកម្ដាយវាកក់ក្ដៅនឹងឯង។

កៈ ចាសចាស!

ខៈ ដល់ពែលយើងនៅតែម្នាក់ឯងវាឯកាចឹងឯង៕ហាហា.

កៈ ចាស!

ខៈ ដល់ពេលឈឺអត់មានអ្នកមើល។

កៈ ចាសអញ្ចឹងពីមុនស្រួយជាងឥឡូវនេះហីអ៊ុំ?

ខ៖ ចាស!

ក៖ ចាស! អញ្ចឹងតើអ៊ុំមាន..ដូចថា, តើអ៊ុំចេះធ្វើម្ហូបទេ?

ខ៖ អ៊ុំអត់សូវចេះដែល៕

ក៖ ចុះម្ដាយរបស់អ៊ុំតើគាត់បានបង្រៀនអីដល់អ៊ុំខ្លះដែលឬអត់?

ខ៖ ចេះតែស្លរធម្មតា។

ក៖ ចាស! អាចធ្វើញាំបានហើអ៊ុំ?

ខ៖ ចាស!

ក៖ ចាស! អញ្ចឹងតើអ៊ុំមានបទចំរៀងណាដែលអ៊ុំចូលចិត្តទេ? រស់សេរីធោធាឬក៏អ្នកណាដែល?

ខ៖ បើនិយាយមិនច្បាស់ផងធ្វើម៉េចច្រៀងកើត?

ក៖ អត់ទេបទដែលអ៊ុំចូលចិត្តហាស? មិនមែណអោយអ៊ុំច្រៀងទេ៕

ខ៖ អញ្ចឹងហ្ន?

ក៖ ចាស! សិលាចាំប្ដីអី? ហាហា

ខ៖ អត់ចេះ អត់ចេះ៕

ក៖ តើអ៊ុំចូលចិត្តបទនឹងដែលឬអត់?

ខ៖ ចូលចិត្ត ចូលចិត្តតែអត់ចេះទេ។

ក៖ ចាស!

ខ៖ និយាយមែន។

ក៖ ចាស! ចុះម្ហូបតើអ៊ុំចូលចិត្តញាំម្ហូបអ្វីជាងគេ?

ខ៖ អ៊ុំហ្ន?

កៈ ចាស!

ខៈ ចូលចិត្តសំឡរម្ជូរ៕

កៈ អូឆ្ងាញ់!!!!

ខៈ ចាស!

កៈ ខ្ញុំក៏ចូលចិត្តដែល។

ខៈ ហាហា...!

កៈ ចុះបើប្រហុកបុកទឹកគ្រឿងអី?

ខៈ ហ៊ី!!! ចូលចិត្តអានឹងចំនាញម៉ង។

កៈ ចាស! អញ្ចឹងតើដល់សព្វថ្ងៃនេះតើអ៊ុំនៅតែចូលចិត្តញ៉ាំម្ហូបនឹងទៀតដែលទេ?

ខៈ ចាស! នៅចូលចិត្ត។

កៈ ចាស! អញ្ចឹងសម័យពីដើមអ៊ុំរស់នៅជាមួយគ្រុមគ្រួសាររបស់អ៊ុំហាស?

ខៈ ចាស!

កៈ តើជីវភាពរបស់គ្រុមគ្រួសាររបស់អ៊ុំយ៉ាងម៉េចដែលធូធារអត់?

ខៈ វាមិនធូធារអីទេ, គ្រាន់ថាយើងនៅជុំគ្នាចឹងហាសវាកក់ក្ដៅវាសប្បាយ។

កៈ ចាសអ៊ុំ!

ខៈ ដល់ពេលដែលអត់ពីពួកគាត់ចឹងវាហែងហាងចឹងហាស?

កៈ ចាសអ៊ុំ! អញ្ចឹងមានផ្ទះមានអីរស់នៅសមរ្យហើយមានអាហារអីហូបចុកគ្រប់គ្រាន់ដែលតើ ហីអ៊ុំនៅកាលនឹង?

ខៈ ចាស!

ក៖ ចាស!

ខ៖ បើនិយាយទៅវាអត់ដែលតែឪពុកយើងគាត់អ្នកផ្តត់ផ្គន់អោយយើងចឹងហាស?

ក៖ ចាសអ៊ុំ!

ខ៖ ចាស!

ក៖ ចាស! លខណ្ឌៈថារស់នៅជុំគ្នាមានភាពកក់ក្តៅ?

ខ៖ ចាស!

ក៖ ចាស! អញ្ចឹងអ៊ុំអាចប្រាប់ខ្ញុំបានដែលទេ? តើពេលវេលាណាដែលអ៊ុំគិតថាពិបាកជាំងគែ ហាស់? តើអ៊ុំបានឆ្លងកាត់វាបានដោយរប្រៀបណាដែល, ពេលដែលឪពុកម្តាយរបស់អ៊ុំស្លាប់ ទៅឬក៏ពេលណាដែលអ៊ុំ?

ខ៖ និយាយម្តងទៀត និយាយថាម៉េច?

ក៖ និយាយថាពេលវេលាណាដែលអ៊ុំគិតថាពិបាកជាងគេ, ពិបាកឆ្លងកាត់ហាស?

ខ៖ ពិបាកឆ្លងកាត់ពេលឈឺ។

ក៖ ចាស! ពេលដែលអ៊ុំឈឺនៅពីក្មេងមែនទេ?

ខ៖ អត់ទេ ទឹមតែឈឺនេះ មុននេះដែល!!

ក៖ ចាស! តើអ៊ុំឈឺអ្វីដែល?

ខ៖ រលាកពោះវៀន, អូមិនរលាកពោះវៀនទេ រលាកក្រពះ។

ក៖ ចាសអ៊ុំ! តែឥឡូវនេះអ៊ុំបានជាធូស្រាលហើយន៍អ៊ុំ?

ខ៖ ចាស ចាស!

ក៖ តើអ៊ុំនៅតែបន្តលេបថ្នាំទៀតដែលឬអត់ឬក៏ឈប់ហើយ?

ខ៖ នៅតែបន្តតើ អោយពេទ្យលីទិញអោយទៅ។ ហើយលេបទៅ។

កៈ ចាស! អញ្ចឹងមានតែមួយនឹងដែលអ៊ុំពិបាកជាងគេន៍អ៊ុំ?

ខៈ ចាស! ពិបាកជាងគេគឺពេលដែលឈឺនឹងឯង។

កៈ ចាសហាហា..!

ខៈ ហាហា.!

កៈ ត្រូវហើយអ៊ុំ!

ខ៖ បើសិនជាអត់ឈឺអត់អីទេ។

កៈ ចាសនិយាយត្រូវអ៊ុំឈឺពិបាកដមើប្បីឆ្លងកាត់ណាស់។

ខៈ ចាសចាស!

កៈ ចាស! ហើយមានអារម្មណ៍ថារស់ហើយនឹងងាប់វាស្មើតែគ្នា។

ខៈ ចាស! ត្រូវហើយ។

កៈ តែបើឆ្លងអាដំណាក់កាលនឹងផុតគឺរួចខ្លួនហើយ លែងអីហើយ។

ខៈ ចាស! លែងអីហើយ។ ហាហា..!

កៈ ចាស! ចុះតើពេលវេលាណាដែលថារីករាយជាងគេនៅក្នុងជីវិតរបស់អ៊ុំ?

ខៈ រីករាយជាងគេគឺពេលដែលអត់ឈឺនឹងឯង។ ហាហា...!

កៈ ចាស! ត្រូវអ៊ុំ។ អញ្ចឹងតើអ៊ុំមានអ្វីទៀតដែឡឬអត់? រស់នៅជាមួយនឹងគ្រុមគ្រួសារឬក៏មានអ្វីញាំគ្រប់គ្រាន់ឬក៏មានសំល្លៀកពាក់ស្អាតៗមានលុយចាយគ្រប់គ្រាន់? តើមានដែលអត់អ៊ុំ?

ខៈ អើ អើ!! វាអត់ទាន់មាន។

កៈ អត់ទាន់មាន។

ខៈ វាអទ់ទាន់មាន។ ហាហា...

កះ ហ៊ី!!! តើអ៊ុំរំពឹងថាចង់បានអ្វីទៅមនុខទៀតទៅជីវិតខាងមុខរបស់អ៊ុំហាស់? ខ្ញុំដឹងថាអ៊ុំរស់នៅតែម្នាក់ឯងចឹងហាស់៕

ខះ ចាស!

កះ ចាស! តើជីវិតរបស់អ៊ុំទៅខាងមុចទៀតអ៊ុំចង់បានយ៉ាងម៉េច?

ខះ អ៊ុំចង់បានតែធូរធានឹងឯង។

កះ ចាស!

ខះ ប៉ុន្តែកុំអោយតែឈឺទៅ។

កះ ចាសចាស!

ខះ មានតែប៉ុននឹងឯង។

កះ ចាស!

ខះ ជីវិតរបស់អ៊ុំមានតែប៉ុននឹងឯង, នឹកឃើញថាយើងកុំអោយឈឺហើយធូរធាទៅវាល្អហើយ។

កះ ចាស!

ខះ វាល្អប្រសើរហាស់?

កះ ចាសអ៊ុំ!

ខះ ចាស!

កះ ចាស! ទោះបីជាជីវិភាពរបស់យ៉ងមិនសូវមានមែណា។ តើបើសិនជាយើងមានសុខភាពល្អយើងសប្បាយចិត្ត។

ខះ ចាសចាស! យើងសប្បាយចិត្ត។

កះ ចាសអ៊ុំ!

ខះ ព្រោះអ្វីមនុស្សវាចឹងមែន។ រឿងនឹងវាត្រូវចឹងមែន។

កៈ ចាសចាស!ប៉ុន្តែខ្ញុំមើលទៅអ៊ុំនៅស្រស់ថ្លាចឹងខ្ញុំជូនពរអោយអ៊ុំមានអាយុវែងហាអ៊ុំ!!

ខៈ ចាសសាធុបសាធុបកូនណា៕

កៈ ចាសចាសអរគុណច្រើនអ៊ុំ។ យើងនៅតែម្នាក់ឯងចឹងផងចាស។

ខៈ ចាស!

កៈ អញ្ចឹងតើអ៊ុំមានអ្វីទៀតដែលអត់?

ខៈ មិនដឹងមានអ្វីទៀតទេក្មួយអើយ, អ៊ុំអត់ចេះស្អីផង។

កៈ ចាស!

ខៈ អត់ចេះមែន, និយាយទៅគឺថាល្ងង់១០ជិតប៉ុនដោយហា។

កៈ ចាសចាស!

ខៈ បើអោយនិយាយអីចេះនិយាយចឹងបាន, តែបើអោយធ្វើស្អីអត់ចេះ។

កៈ ចាសអ៊ុំ! តែអ៊ុំនិយាយបានច្រើនដែល។

ខៈ ចាស ហាហា...!

កៈ ចាស! អញ្ចឹងខ្ញុំក៏អស់អ្វីសួរទៅអ៊ុំដែលហើយ។

ខៈ ចាស! អញ្ចឹងខ្ញុំសូមអរគុណអ៊ំមច្រើន។

ខៈ ចាស! អាយុវែងណាក្មួយ។

កៈ ចាសអ៊ុំ! អរគុណអ៊ុំដែលបានចំណាយពេលអោយខ្ញុំថ្ងៃនេះ។

ខៈ ចាស!

កៈ អញ្ចឹងពីមនុននឹងបញ្ចប់ទៅខ្ញុំសូមធ្វើការថតរូបអ៊ុំមួយតើបានដែលទេ?

ខៈ ចាស! អ៊ុំសូមជូតទឹកភ្នែកអ៊ុំមួយសិនណាស់៕

កៈ ចាសអ៊ុំ!